*រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៩៤*

# អនុក្រឹត្យលេខ ៦៨ អនក្រ
# ស្តីពីលិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជាពិសេសមាត្រា ១២៦
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងស្មារតីប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ១៩៩៤
- តាមសំណើរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និង ក្រសួងមហាផ្ទៃ ។

## សំរេច

## ជំពូក ១

## បទបញ្ញត្តិទូទៅ

**មាត្រា ១ :** ត្រូវបានបង្កើតលិខិតឆ្លងដែនដែលមាន ៤ ប្រភេទ :

ក_លិខិតឆ្លងដែនការទូត

ខ_លិខិតឆ្លងដែនផ្លូវការ

គ_លិខិតឆ្លងដែន ( ធម្មតា )

ឃ_លិខិតធ្វើដំណើរ

លក្ខណៈនៃលិខិតឆ្លងដែនត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងការ បរទេស និងសហប្រតិបត្តិការអន្តរជាតិ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

# ជំពូក ២
# អំពីលិខិតឆ្លងដែនការទូត

**មាត្រា ២ :** លិខិតឆ្លងដែនការទូតសំរាប់មន្ត្រីរាជការ ទៅតាមលំដាប់សក្តិដូចមានខាងក្រោម ÷

១_ព្រះមហាក្សត្រ ព្រះមហេសី និងព្រះរាជបុត្រា បុត្រី ។

២_សមាជិក សមាជិកានៃរដ្ឋសភា

៣_មន្ត្រីសង្ឃ មន្ត្រីរាជការដែលមានមុខតំណែងតែងតាំងដោយព្រះរាជក្រឹត្យ ។

៤_នាយក អគ្គលេខាធិការ នៃព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ ។

៥_អគ្គលេខាធិការនៃរដ្ឋសភា ។

៦_ទីប្រឹក្សាព្រះមហាក្សត្រ ប្រធានរដ្ឋសភា អនុប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រី ។

៧_នាយកខុទ្ទកាល័យ ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ។

៨_អតីតប្រធានសភា អតីតនាយករដ្ឋមន្ត្រី អតីតរដ្ឋមន្ត្រីការបរទេស ។

៩_មន្ត្រីក្របខ័ណ្ឌការទូត ។

១០_ភរិយា ប្តី កូនប្រុសស្រី នៅលីវដែលមានអាយុក្រោម ១៨ ឆ្នាំ មានសិទ្ធិកាន់លិខិតឆ្លងដែនការទូតដូចប្តី ប្រពន្ធ ឪពុក ម្តាយដែរ ។

**មាត្រា ៣ :** ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានភារកិច្ចចេញលិខិតឆ្លងដែនការទូត ។

**មាត្រា ៤ :** សុពលភាពនៃលិខិតឆ្លងដែនការទូត មានរយៈពេលដំបូង ៣ ឆ្នាំ ហើយអាចបន្តសំរាប់រយៈពេលរាល់ ២ ឆ្នាំម្តង ។ ផុតរយៈពេល ៧ ឆ្នាំដោយគិតពីថ្ងៃចេញលើកដំបូង ចាំបាច់ត្រូវធ្វើលិខិតឆ្លងដែនថ្មីមួយទៀត ។

# ជំពូក ៣
# អំពីលិខិតឆ្លងដែនផ្លូវការ

**មាត្រា ៥ :** លិខិតឆ្លងដែនផ្លូវការសំរាប់មន្ត្រីរាជការទូទៅ ដែលត្រូវចេញទៅបំពេញបេសកកម្ម ជាផ្លូវការនៅបរទេស ។

**មាត្រា ៦ :** លិខិតឆ្លងដែនផ្លូវការ ត្រូវចេញដោយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

**មាត្រា ៧ :** លិខិតឆ្លងដែនផ្លូវការមានសុពលភាព និងរយៈពេលពន្យារដូចគ្នា និងលិខិតឆ្លងដែនការទូតដែរ ។

## ជំពូក ៤

## អំពីលិខិតឆ្លងដែន ( ធម្មតា )

**មាត្រា ៨ :** លិខិតឆ្លងដែន ( ធម្មតា ) សំរាប់ផ្តល់ជូនពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុចាប់ពី ១៨ ឆ្នាំ ឡើងទៅ សំរាប់ធ្វើ ដំណើរទៅបរទេស ។

កុមារអាយុតិចជាង ១៨ ឆ្នាំ អាចស្នើសុំលិខិតឆ្លងដែននេះផ្ទាល់ខ្លួនបាន បើមាន ការ អនុញ្ញាត ជាលាយល័ក្ខអក្សរពីឪពុក ម្តាយ ឬអាណាព្យាបាល ដោយមានភ្ជាប់ប័ណ្ណ សំគាល់គ្រួសារ ឬ សំបុត្រ កំណើតភ្ជាប់មកជាមួយពាក្យសុំលិខិតឆ្លងដែនរបស់ សាម៉ីខ្លួន ។

ក្នុងករណីមានអាយុតិចជាង ១២ ឆ្នាំ ហើយធ្វើដំណើររួមជាមួយឪពុក ម្តាយ ឬ អាណាព្យាបាលកុមារទាំងនោះ ត្រូវចុះក្នុងលិខិតឆ្លងដែន ឬ ឯកសារធ្វើដំណើររបស់ឪពុកម្តាយឬ អាណាព្យាបាល ។

**មាត្រា ៩ :** ក្រសួងមហាផ្ទៃមានសមត្ថកិច្ចចេញលិខិតឆ្លងដែននេះ លើកលែងតែមានចែងក្នុងមាត្រា ១៦ ។

**មាត្រា ១០ :** លិខិតឆ្លងដែន ( ធម្មតា ) មានសុពលភាពរយៈពេលពន្យារដូចគ្នា និងលិខិតឆ្លងដែនការទូតដែរ ។

**មាត្រា ១១ :** អាករលើលិខិតឆ្លងដែននេះ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

## ជំពូក ៥

## អំពីលិខិតធ្វើដំណើរ

**មាត្រា ១២ :** លិខិតធ្វើដំណើរអាចផ្តល់អោយជនដែលគ្មានសញ្ជាតិខ្មែរ ដែលបំពេញលក្ខខណ្ឌចែងក្នុងជំពូក ៤ នៃច្បាប់អន្តោប្រវេសន្ត ។

**មាត្រា ១៣ :** ក្រសួងមហាផ្ទៃមានសមត្ថកិច្ច ចេញលិខិតធ្វើដំណើរនេះ ។

**មាត្រា ១៤ :** លិខិតធ្វើដំណើរនេះ មានសុពលភាពដែលត្រូវសំរេចដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តែសុពលភាពនេះពុំអាចលើសពី ៣ ឆ្នាំបានឡើយ ។ ក្រសួងមហាផ្ទៃមានអំណាចដកហូតលិខិតធ្វើដំណើរ ពីសាមីខ្លួនក្នុងករណីចាំបាច់ ។

**មាត្រា ១៥ :** អាករលើលិខិតធ្វើដំណើរនេះ ត្រូវកំណត់ដោយប្រកាសរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូក ៦

## សមត្ថកិច្ចស្ថានទូត ស្ថានអគ្គកុងស៊ុល ស្ថានតំណាងចេញលិខិតឆ្លងដែន

**មាត្រា ១៦ :** ស្ថានទូត អគ្គកុងស៊ុល ស្ថានតំណាង មានសិទ្ធចេញលិខិតឆ្លងដែនការទូត លិខិតឆ្លងដែនផ្លូវការ និងលិខិតឆ្លងដែន (ធម្មតា ) បន្ទាប់ពីបានទទួលការអនុញ្ញាតយល់ព្រមពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

## ជំពូក ៧

## អវសានប្បញ្ញត្តិ

**មាត្រា ១៧** ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងមហាផ្ទៃ មានសិទ្ធិបដិសេធនូវលិខិតឆ្លងដែន ដែលបាត់បង់ ឬក្លែងបន្លំ ។

**មាត្រា ១៨ :** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៩:** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋានត្រូវទទួលអនុវត្តអ នុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណប្ញទ្ធិ** | **ហ៊ុន សែន** |

***